ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សមិទ្ធផល




## អប់រំ យុវជន និងកីឡា

ឆ្នាំសិក្សា២០១១ - ២០១២

ខែមីនា ឆ្នាំ២០១៣

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យប្រទេសកម្ពុជាមានសន្តិភាពពេញលេញ តាមរយៈនយោបាយឈ្នះឈ្នះ និងមានការអភិវឌ្ឍគួរជាទីមោទនៈ។

ក្នុងអាណត្តិទី៤ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានបន្តអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងកំណែទម្រង់តាមការដ្ឋានសំខាន់ៗរបស់រាជរដ្ឋាភិបាលនាំមកនូវការរីកចម្រើនជាបន្តបន្ទាប់លើគ្រប់វិស័យ។






ដោយឡែកដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ដោយផ្តោតលើគោលនយោបាយគន្លឹះសំខាន់ៗរួមមាន ៖

១) ការទទួលបានសេវាអប់រំប្រកបដោយសមធម៌

២) ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការអប់រំ

៣) ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។





ជាលទ្ធផលក្នុងឆ្នាំសិក្សា២០១១-២០១២ យើងសម្រេចបាន ៖

- កសាងអគារសិក្សាជាច្រើននៅគ្រប់ច្រកល្ហកទូទាំងប្រទេស និងពិនិត្យលទ្ធភាពការកសាងគ្រឹះស្ថានឧត្តមសិក្សានៅតាមបណ្តាខេត្តក្នុងគោលដៅ បង្កិតសាលារៀនឱ្យទៅជិតលំនៅដ្ឋានរបស់ប្រជាពលរដ្ឋស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

- កែលម្អលិខិតបទដ្ឋានដែលមានស្រាប់ និងកសាងលិខិតបទដ្ឋានថ្មីៗ ព្រមទាំងរៀបចំគោលនយោបាយនានាដូចជា គោលនយោបាយស្តីពីគ្រូបង្រៀន គោលនយោបាយជាតិអភិវឌ្ឍយុវជន គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យនៅឧត្តមសិក្សា សំដៅឆ្លើយតបទៅនឹងច្បាប់ស្តីពីការអប់រំ ដែលជាត្រីវិស័យក្នុងការតម្រង់ទិសវិស័យអប់រំឆ្ពោះទៅការកែទម្រង់ស៊ីជម្រៅក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលធនធានមនុស្ស។













មកដល់បច្ចុប្បន្ននេះ យើងមានសាលារៀនចំណោះទូទៅចំនួន ១១ ៣៧០ នៅទូទាំងប្រទេស។

- ដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សាទុតិយភូមិ និងផ្តល់សៀវភៅសិក្សាដល់សិស្សនៅទូទាំងប្រទេស។

- បោះពុម្ពសៀវភៅកម្មវិធីសិក្សាលម្អិតបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ថ្នាក់ទី១១ និងថ្នាក់ទី១២។







- ធ្វើវិក្រឹតការគ្រូបង្រៀនជាប្រចាំ ដើម្បីផ្តល់ការអប់រំ ដល់យុវជនជំនាន់ក្រោយឱ្យកាន់តែមានចំណេះដឹង បំណិន និងសីលធម៌ខ្ពស់ស្របតាមចតុស្តម្ភទាំង៤ នៃគោលការណ៍អប់រំ គឺរៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរួមរស់នៅជាមួយគ្នា។



- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអប់រំ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអភិបាលកិច្ចល្អនៅក្នុងវិស័យអប់រំ។

- រៀបចំឱ្យមានយន្តការធានាគុណភាពអប់រំ ដើម្បីពិនិត្យ និងវាយតម្លៃលើការងារសិក្សា និងការងារគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា។

# ការខារអប់រំកុមារតូច

យើងមានមត្តេយ្យសិក្សាគ្រប់រូបភាព ៥ ៤៦៧ កើន ៣៤២កន្លែង ក្នុងនោះមត្តេយ្យសិក្សារដ្ឋ ២ ៨១៣ មត្តេយ្យសិក្សាឯកជន ៣៤៨ និងមត្តេយ្យសិក្សាសហគមន៍ ២ ៣០៩ ។ ថ្នាក់រៀនសរុប ៨ ០៩០ ដែលទទួលកុមារក្រោមអាយុ ៦ឆ្នាំ ៣១១ ១៥៤នាក់ ស្រី៤៩,៩៨ភាគរយ ។









ក្រសួង បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច។ បានរៀបចំសេចក្តីព្រាងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល សម្រាប់អនុវិស័យអប់រំកុមារតូច។

សកម្មភាពអប់រំពីរភាសាសាកល្បងចំនួន ២០ កន្លែងក្នុងខេត្តចំនួន៥ រួមមាន ៖ ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ។ នៅក្នុងសកម្មភាពអប់រំ២ ភាសា មានភាសាព្នង ទំពួន គួយ គ្រឹង និងចារាយ។ ការអនុវត្តគម្រោងនេះមានការជួយផ្នែកបច្ចេកទេសពីអង្គការឃែរ និងឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វ។







សកម្មភាពការអប់រំបញ្ចូលគ្នា បានសាកល្បងអនុវត្តចំនួន៤៨កន្លែង ក្នុងខេត្តចំនួន៣ ខេត្តកំពង់ធំ ព្រៃវែង និងបាត់ដំបង។ ការអនុវត្តគម្រោងនេះ មានការជួយផ្នែកបច្ចេកទេសពីអង្គការជនពិការអន្តរជាតិ និងឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វ។






ដោយផ្អែកលើបទពិសោធន៍ កុមារដែលបានចូលរៀនកម្មវិធីអប់រំកុមារតូចនៅអាយុ៥ឆ្នាំ តែងតែត្រៀមខ្លួនបានល្អសម្រាប់ទទួលការអប់រំនៅបឋមសិក្សា រៀនបានពូកែ និងមិនបោះបង់ការសិក្សា ។

## ការងារបឋមសិក្សា

ដើម្បីដោះស្រាយសំណូមពររៀនសូត្រឱ្យកុមារគ្រប់អាយុបានចូលរៀន ក្រសួងបាននិងកំពុងខិតខំប្រឹងប្រែងសាងសង់សាលានៅតាមតំបន់ដាច់ស្រយាល តាមតំបន់ជួបការលំបាក។ ចំពោះតំបន់លិចទឹក ក្រសួងបានបង្កើតឱ្យមានសាលារៀនបណ្តែតទឹកនិងបានបន្តកាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់កម្រិត។








យើងមានសាលារៀនចំនួន ៦ ៩១០ កើន ៦១សាលា ក្នុងនោះកម្រងសាលាមាន ១ ១៨៨ កើន ២៣។ សាលាកុមារមេត្រី ៤ ៩៨០ កើន ៤៦៨។ សាលាបឋមសិក្សាមិនគ្រប់កម្រិត ៩៥២ នៃចំនួនសាលាបឋមសិក្សាសរុប ។ សាលាបណ្តែតទឹកមានចំនួន ៣៨កន្លែង នៅខេត្តចំនួន ៥ ជុំវិញបឹងទន្លេសាប។

សិស្សចំនួន ២ ១៧៣ ៣៨៤នាក់ ស្រី ៤៧,០៦ភាគរយ។ អត្រាពិតនៃការសិក្សា ៩៧ភាគរយ លើចំណុចដៅផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៩៦ភាគរយ។

ចំនួនក្រុង-ស្រុក-ខណ្ឌ ដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច៨០ភាគរយ មាន១១៥ស្រុក លើ ១៩៤ស្រុក លើចំណុចដៅ ១១៥ស្រុក។

## ការខារមធ្យមសិក្សា

យើងមានគ្រឹះស្ថានមធ្យមសិក្សាចំនួន ១ ៦៤៧ ក្នុងនោះអនុវិទ្យាល័យចំនួន ១ ២១៤ និង វិទ្យាល័យចំនួន ៤៣៣ កើន ១៩សាលា ។ សាលាមធ្យមសិក្សាធនធានមានចំនួន ២៦ ក៏ត្រូវបាន ដាក់ឱ្យដំណើរការផងដែរ។







អតីតកាលជូរចត់ បច្ចុប្បន្នកាលនឿយហត់ អនាគតរុងរឿង

សិស្សមធ្យមសិក្សាបឋមភូមិមានចំនួន ៥៣៤ ៧១០នាក់ ស្រី ៤៩,២៥ភាគរយ ។ អត្រាឡើងថ្នាក់ ៧៨,៥ភាគរយ ស្រី ៨០,៣ភាគរយ។ សិស្សមធ្យមសិក្សាទុតិយភូមិមានចំនួន ២៨៨ ៧៨៩នាក់ ស្រី ៤៦,៦១ភាគរយ ។ អត្រាឡើងថ្នាក់ ៨៨,២ ភាគរយ ស្រី ៨៩,១ភាគរយ ។

ក្នុងឆ្នាំសិក្សា២០១១-២០១២ លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានចំនួន ៩៣,៤៥ ភាគរយ ស្រី ៩៥,៥៦ ភាគរយ និងសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមាន ចំនួន ៨៦,៤៨ ភាគរយ ស្រី ៩១,៥៥ ភាគរយ ។





ក្រសួង បានបញ្ជូនសិស្ស១០នាក់ ទៅចូលរួមប្រកួតប្រជែងផ្នែកវិទ្យាសាស្ត្រគណិតវិទ្យានិងវិទ្យាសាស្ត្រ វ័យក្មេងអន្តរជាតិក្រោមអាយុ១៦ឆ្នាំ ជាលទ្ធផលសិស្សកម្ពុជាជាប់ជាជ័យលាភីចំនួន៨នាក់ បានទទួល មេដាយប្រាក់៥ មេដាយសំរឹទ្ធ១ និង២នាក់ទៀតទទួលបានពានរង្វាន់ល្អប្រសើរបំផុតផ្នែកគណិតវិទ្យា និង ពានរង្វាន់។ ក្រសួងសង្ឃឹមថា អ្នកវិទ្យាសាស្ត្រវ័យក្មេងនឹងទទួលបានជោគជ័យបំផុតនាពេលអនាគត។



# ការអប់រំក្រៅប្រព័ន្ធ

ជាអនុវិស័យមួយមានសារៈសំខាន់ និងចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្តល់ឱកាសដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់វ័យ ដែលពុំបានទទួលការអប់រំក្នុងប្រព័ន្ធ ។





ក្នុងឆ្នាំសិក្សា ២០១១-២០១២ ថ្នាក់អក្ខរកម្មវិជ្ជាជីវៈមានចំនួន ១ ៨៨៩ ថ្នាក់ មានគ្រូអក្ខរកម្ម ១ ៩១២ នាក់ ស្រី ៥១៨នាក់ មានអ្នកចូលរៀន ៣៥ ៩២៥នាក់ អ្នករៀនបានបញ្ចប់កម្មវិធីមានចំនួន ២៦ ៨៩០នាក់ ត្រូវជា ៧៥,៩០ភាគរយ ស្រី ១៧ ៨៨១នាក់។ មូលដ្ឋាននៃការសិក្សា និងតម្រូវការរបស់យុវជននៅក្រៅសាលា ជនពេញវ័យ និងសមាជិកសហគមន៍ មិនគ្រាន់តែឆ្លងផុតពីគ្រោះមិនចេះអក្សរប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវការនូវការអប់រំបន្ត ក៏ដូចជាការបណ្តុះបណ្តាលជំនាញមុខរបរថែមទៀត តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍ ដើម្បីកែលម្អ និងលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ឱ្យកាន់តែប្រសើរ។

ចំពោះលទ្ធផលមធ្យមសិក្សាបំពេញវិជ្ជាវិញ គឺចែកចេញជា២កម្រិត ៖



១-កម្រិតមធ្យមសិក្សាបឋមភូមិយើងមានចំនួន ៣៨ថ្នាក់ មានសិស្សចូលរៀន ១ ៣៣០នាក់ ស្រី ២៦៣នាក់។ បេក្ខជនបំពេញវិជ្ជា និងស្វ័រិនមកប្រឡង ១ ២៥៤ នាក់ ស្រី ២៥០នាក់ បេក្ខជនប្រឡងជាប់សរុប ៨៩២នាក់ ស្រី ១៩៨នាក់។



២-កម្រិតមធ្យមសិក្សាទុតិយភូមិ យើងមាន ២០៤ ថ្នាក់ សិស្សចូលរៀន ៩ ៧៨៥នាក់ ស្រី ២ ៩៣០ នាក់ បេក្ខជនបំពេញវិជ្ជាមកប្រឡង ១០ ១៧៥នាក់ ស្រី ៣០៩១នាក់ បេក្ខជនប្រឡងជាប់ ៧ ១៤៥នាក់ ស្រី ២៤៨២នាក់។

# ការអប់រំឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមានចំនួន ១០១ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៣៩ និងឯកជន ៦២។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ២១៦ ០៣៥នាក់ ស្រី ៨៦ ២៣៥នាក់។ និស្សិតប្រឡងបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា ២០១១-២០១២ ថ្នាក់បរិញ្ញាបត្រសរុបចំនួន ៣៤ ៩៧៨នាក់ ស្រី ១៤ ៤៣២នាក់។











ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មាននិស្សិតកំពុងសិក្សាមានចំនួន ១៤ ៩៩៧នាក់ ស្រី ២ ៨៨៥នាក់ និងបានបញ្ចប់ការសិក្សាមានចំនួន ៥ ៣៨១នាក់ ស្រី ១ ២១៤នាក់។ ថ្នាក់បណ្ឌិតកំពុងសិក្សាមានចំនួន ១ ០៦៣នាក់ ស្រី ៥៧នាក់ និងបានបញ្ចប់ការសិក្សាមានចំនួន ៤៧នាក់ ស្រី ១នាក់។





**ពិធីអបអរសាទរ**

ទិវាអន្តរជាតិនារី ៨ មីនា ខួបទី១០២ ឆ្នាំ២០១៣

ប្រធានបទ **សិទ្ធិស្មើគ្នា ឱកាសដូចគ្នា ដើម្បីពន្លឿនកម្មអភិវឌ្ឍន៍**

ក្រោមអធិបតីភាព ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង **លោកជំទាវ**

កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា







## ការងារអភិវឌ្ឍយុវជន និងកុមារ

ក្រសួងបានបង្កើតក្រុមប្រឹក្សាយុវជន និងកុមារ នៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា និងបង្កើតក្លឹបក្នុងគោលបំណងអភិវឌ្ឍយុវជន និងកុមារ តាមរយៈការអនុវត្តចលនាប្រឡងប្រណាំងពល្អ « កូនល្អ សិស្សល្អ មិត្តល្អ » ដើម្បីអភិវឌ្ឍរូបរាងកាយ គំនិតបញ្ញា និងស្មារតី។ ក្រៅពីនោះ បានរៀបចំបោះជំរុំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ស្តីពីការសិក្សាអប់រំ ការឆ្លងមេរោគអេដស៍ ជំងឺកាមរោគ សុខភាពបន្តពូជ ការប្រើគ្រឿងញៀន ច្បាប់ចរាចរណ៍ ធ្វើទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស និងបានចូលរួមការងារសង្គម។









ការងារទាំងនេះមានសារៈសំខាន់ក្នុងការអភិវឌ្ឍយុវជនឱ្យចូលរួមយ៉ាងសកម្ម និងប្រកបដោយគុណភាពក្នុងការអភិវឌ្ឍសង្គម ។

**យុវជនជាសសរទ្រូងរបស់ប្រទេសជាតិ**

# ការចុះសួរសុខទុក្ខក្រុមវីរៈយុវជនស្ម័គ្រចិត្តសម្តេចតេជោ





ក្នុងពិធីចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយក្រុមវីរៈយុវជនស្ម័គ្រចិត្តសម្តេចតេជោ នៅខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានកោតសរសើរចំពោះការលះបង់របស់ក្មួយៗយុវជនស្ម័គ្រចិត្តទាំងអស់ ដើម្បីបុព្វហេតុវាស់ដីធ្លីជូនប្រជាពលរដ្ឋ និងបាននាំយកគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនចែកជូនដល់ក្រុមវីរៈយុវជនស្ម័គ្រចិត្តសម្តេចតេជោ ។







យើងនៅឲ្យគេស្រឡាញ់ ពេលត្រឡប់ទៅវិញឲ្យគេរលឹក

# ការផ្សារភ្ជាប់សមរភូមិមុខ និងសមរភូមិក្រោយ





ប្រាសាទព្រះវិហារត្រូវបានដាក់ចូលក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨

ប្រតិភូក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានចុះសួរសុខទុក្ខអង្គភាពកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ប្រចាំការនៅទិសប្រាសាទព្រះវិហារ ដែលមានទីតាំងស្ថិតនៅឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងកងទ័ពប្រចាំការនៅលើកំពូលភ្នំប្រាសាទព្រះវិហារ បាននាំយកនូវថវិកា គ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ប្រគល់ជូនដល់អង្គភាពកងទ័ពដែលបានឈរជើងនៅតាមគោលដៅ។














គាំទ្រដាច់ខាតចំពោះ បេក្ខភាពតែមួយគត់គឺ សម្តេច ហ៊ុន សែន
ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៥!





## ការអប់រំកាយ និងកីឡា

ក្រសួងបានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងកីឡាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការធ្វើសិក្ខាសាលា និងបានកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡានៅតាមបណ្ដាខេត្តមួយចំនួន។ ទន្ទឹមនឹងនេះ ក្រសួងបានសហការជាមួយសហព័ន្ធកីឡានានា រៀបចំការប្រកួតកីឡាមហាជន និងការប្រកួតជ្រើសរើសជើងឯកភូមិភាគលើប្រភេទកីឡាបាល់ទាត់ បាល់ទះ បាល់បោះ និងអត្តពលកម្ម ស្របតាមគោលដៅ " **កីឡាដើម្បីទាំងអស់គ្នា** " រួមគ្នាលើកកម្ពស់សុខភាព និងសាមគ្គីភាព។




ក្រសួង បានបញ្ជូនកីឡាករ កីឡាការិនីចំនួន១២ ប្រភេទកីឡា ទៅចូលរួមការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ។ ជាលទ្ធផលកីឡាករ កីឡាការិនីកម្ពុជា ទទួលបានមេដាយមាស២ មេដាយប្រាក់៤ មេដាយសំរឹទ្ធិ ១៧ និង ពានរង្វាន់សមាគម។



# ការសាងសង់អគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធអប់រំ

ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីអមដំណើរចុះពិនិត្យការដ្ឋានសាងសង់អគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធអប់រំ ។

























## ការងារសហប្រតិបត្តិការ

តាមរយៈកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ពិសេសកិច្ចប្រជុំកំពូលអាស៊ីបូ៉ាលើកទី៧ ដែលបានប្រារព្ធធ្វើពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ប្រមុខរដ្ឋាភិបាលនៃប្រទេសអាស៊ាន និងប្រទេសដៃគូសន្ទនាអាស៊ាន បានសម្តែងនូវការស្វាគមន៍ដល់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអប់រំអាស៊ីបូ៉ាលើកទី១ កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ នៅទីក្រុង Yogyakarta នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ដែលបានគាំទ្រផែនការសកម្មភាពអប់រំអាស៊ីបូ៉ា និងទទួលស្គាល់សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអប់រំប្រកបដោយផ្លែផ្កា និងវិបុលភាពក្នុងតំបន់។





ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ទទួលបដិសណ្ឋារកិច្ចឯកឧត្តម **បារ៉ាក់ អូបាម៉ា** ប្រធាននាធិបតីសហរដ្ឋអាមេរិក អញ្ជើញមកចូលរួមកិច្ចប្រជុំ អាស៊ាន-អាមេរិក លើកទី៤ នៅវិមានសន្តិភាព រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ ។






ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង **លោកជំទាវ** បានទទួលបដិសណ្ឋារកិច្ច
ឯកឧត្តម Susilo Bambang Yudhoyono ប្រធានាធិបតីសាធារណរដ្ឋឥណ្ឌូណេស៊ី និង **លោកជំទាវ**
អញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី២១
នៅវិមានសន្តិភាព រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ ។

ការលើកកម្ពស់កិច្ចសហប្រតិបត្តិការវិស័យអប់រំ យុវជន និងកីឡា ត្រូវបានធ្វើឡើងតាមរយៈការអនុវត្តកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសសមាជិកស៊ីមេអូ-អាស៊ាន ហ្វ្រង់កូហ្វូនី ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សអន្តរជាតិ ព្រមទាំងវិស័យឯកជនផង ក្រោមរូបភាពកិច្ចសហប្រតិបត្តិការអប់រំទ្វេភាគី និងពហុភាគី។





ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទទួលជួបសម្តែងការគួរសមជាមួយឯកឧត្តមបណ្ឌិត PEHIN ABU BAKAR APONG ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ និងជារដ្ឋមន្ត្រីក្រសួងអប់រំ ប្រទេសប្រ៊ុយណេដារ៉ូសាឡឹម កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។ ជំនួបពិភាក្សានេះ មានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ វប្បធម៌ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យានៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន។





ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង ឯកឧត្តម **ស៊ឺហ្គេ ម៉ាស្កេវិច** (Sergei MASKEVICH) រដ្ឋមន្ត្រីក្រសួងអប់រំនៃសាធារណរដ្ឋបេឡារុស្ស បានចុះហត្ថលេខាលើលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិស័យអប់រំរវាងប្រទេសទាំងពីរ ព្រះរាជណាចក្រកម្ពុជា និងសាធារណរដ្ឋបេឡារុស្ស កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ។




សន្និសីទកំពូលនៃបណ្តាប្រទេសនិយាយភាសាបារាំងលើកទី១៤ នៅទីក្រុងគីនសាសានៃសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ រយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១២ នៅវិមានប្រជាជន ដោយមានការចូលរួមពីប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលចំនួន ៧៥ ប្រទេស។






កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់អ្នកពាក់ព័ន្ធ ស្តីពីការរៀបចំកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០១៤-២០១៦ និងការប្រគល់មូលប្បទានបត្រ មានទឹកប្រាក់ចំនួន ៦,៩១៤,២៨៥.០០ អឺរ៉ូ ដែលសហភាពអឺរ៉ុបបានផ្តល់ឱ្យក្រសួងអប់រំ យុវជន និងកីឡា អនុវត្តគម្រោងក្នុងឆ្នាំ២០១២ កន្លងមក។



 

ឯកឧត្តម **អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
អញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយជាផ្លូវការកម្មវិធីភាពជាដៃគូរវាង
វិទ្យាស្ថានអន្តរជាតិផែនការអប់រំ-IIEP និងវិទ្យាស្ថានជាតិអប់រំ-NIE សាកលវិទ្យាល័យភូមិន្ទភ្នំពេញ-RUPP
និងនាយកដ្ឋានផែនការ-DOP នៃក្រសួងអប់រំ យុវជន និងកីឡា
(Launching Conference of Twinning Program between IIEP – NIE/RUPP/DoP)
កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ នៅវិទ្យាស្ថានជាតិអប់រំ

 

ពិធីចុះហត្ថលេខាលើកំណត់ហេតុពិភាក្សា

ស្តីពី

ការអនុវត្តគម្រោងអភិវឌ្ឍការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ
ដែលមានទឹកប្រាក់ចំនួន ២ លានដុល្លារសហរដ្ឋអាមេរិក ដោយឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងលោក Shin EUI - CHEOL ប្រធានក្រុមប្រតិបត្តិទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ។

## កិច្ចសហប្រតិបត្តិការនាំមកនូវការអភិវឌ្ឍន៍






ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
អញ្ជើញជាអធិបតីក្នុងពិធីប្រគល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររបស់អង្គការមូលនិធិ **ឌី.ខេ.គីម** កម្ពុជា
ជូននិស្សិតក្រីក្រកម្ពុជា
កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១២ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា



ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់គម្រោង
ស្តីពី
ការពង្រឹងសមត្ថភាពអប់រំពីចម្ងាយនៅកម្ពុជាសម្រាប់អាស៊ានសាយប៊ឺយូនីវើស៊ីធី
កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម William E.Todd ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក Dave Gordge តំណាងស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីភាពក្នុងពិធីបើកសន្និសីទ CamTESOL ប្រចាំឆ្នាំលើកទី ៩ ស្តីពីការបង្រៀនភាសាអង់គ្លេស ដែលមានរយៈពេល២ថ្ងៃចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០១៣ នៅវិទ្យាស្ថានជាតិអប់រំ ។






ពិធីចុះហត្ថលេខារវាងក្រសួងអប់រំ យុវជន និងកីឡា និង អង្គការយូនីសេហ្វប្រចាំនៅកម្ពុជា ដោយឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងលោកស្រី Sun Ah Kim Suh តំណាងអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា ដែលមានទឹកប្រាក់ចំនួន ៣,១៩៤,១៨៦ ដុល្លាសហរដ្ឋអាមេរិក សម្រាប់អនុវត្តគម្រោងផែនការប្រចាំឆ្នាំ២០១២។ គម្រោងនេះ គឺមានគោលបំណងសំខាន់សម្រាប់ជួយដល់ការងារអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តោតទៅលើ ៖

ការពង្រឹងដំណើរការពិគ្រោះយោបល់គោលនយោបាយ និងការសម្របសម្រួលដើម្បីលើកកម្ពស់សមធម៌ក្នុងវិស័យអប់រំ ពង្រឹងការងារអប់រំកុមារតូច និងការអប់រំនៅបឋមសិក្សា ។



ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងបន្តសម្រាប់ឆ្នាំ ២០១៣-២០១៥ រវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិអាស៊ីប្រចាំនៅកម្ពុជា ស្តីពីគម្រោងផ្តល់សៀវភៅភាសាអង់គ្លេសចំនួន ១៥០.000 ក្បាល ដែលមានទឹកប្រាក់ចំនួន ៩,៧៧៧,៤៧៦.០០ ដុល្លាអាមេរិក ដោយឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួអប់រំ យុវជន និងកីឡា និងលោក Silas Everett តំណាងអង្គការមូលនិធិអាស៊ីប្រចាំនៅកម្ពុជា កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ។



ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អញ្ជើញជាអធិបតីភាពក្នុងពិធីផ្សព្វផ្សាយកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា នៅអនុវិទ្យាល័យបន្ទាយខ្មែរ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលព្រឹកថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ ។










ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និសីទអន្តរជាតិលើកទី ២ ស្តីពីគណិតវិទ្យា និងការប្រើបច្ចេកវិទ្យាក្នុងការអប់រំគណិតវិទ្យា កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៣ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា - ជប៉ុន ។








ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដុនបូស្កូ កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣ នៅក្រុងកែប ខេត្តកែប ។












សមិទ្ធផលទាំងនេះ ជាការបញ្ជាក់ឡើងវិញនូវការបន្តប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការសម្រេចឱ្យបាននូវកម្មវិធីនយោបាយដែលបានដាក់ចេញសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ដោយមានកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បុគ្គលិកអប់រំក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ ដើម្បីបំពេញភារកិច្ចក្នុងការជំរុញ និងលើកស្ទួយកិច្ចអភិវឌ្ឍវិស័យអប់រំ ក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរៀងៗខ្លួន។ យើងសង្ឃឹមថា វិស័យអប់រំនៅកម្ពុជា ពិតជានឹងឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍសហសវត្សរ៍ ។

## ពេលវេលាជាមាសប្រាក់